ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ២៦៣ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី០៣....ខែកក្កដា ឆ្នាំ២០០៧

# ប្រកាស
## ស្តីពី
## លក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញ អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពី សម្បទានដីសង្គមកិច្ច
- បានឃើញ លិខិតលេខ ៧០៤ ជនស/LASED ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ របស់ប្រធានគណៈកម្មាធិការសម្បទានដី សង្គមកិច្ចថ្នាក់ជាតិ ។

## ស ម្រ េ ច

**ប្រការ១** : ប្រកាសនេះ កំណត់អំពីលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់មុខសញ្ញាសុំដីសម្បទានសង្គមកិច្ច ដូចមានចែងក្នុងមាត្រា ១០ ចំណុច (គ) នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពី សម្បទានដីសង្គមកិច្ច ។

**ប្រការ២ :** មុខសញ្ញា ដែលអាចសុំដីសម្បទានសង្គមកិច្ចបានដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៣ ស្តីពី សម្បទានដីសង្គមកិច្ច និងត្រូវយកចិត្តទុកដាក់ដល់មុខសញ្ញាគ្រួសារក្រីក្រ គ្រួសារជនពិការ គ្រួសារដែលមានស្ត្រីមេម៉ាយជាមេគ្រួសារដែលគ្មានដី គ្រួសារក្រីក្រគ្មានដីសម្រាប់ធ្វើកសិកម្ម គ្រួសារអតីតយុទ្ធជន និងគ្រួសារយោធិនរំសាយដែលគ្មានដី និងជនអនាថា ជនរងគ្រោះដោយប្រការផ្សេងៗ នៅតាមមជ្ឈមណ្ឌលសង្គមកិច្ចនានា ដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ហើយបានរស់នៅមូលដ្ឋាននោះរយៈពេល ១ ឆ្នាំ ។

**ប្រការ៣ :** អ្នកសុំដីសម្បទានសង្គមកិច្ចត្រូវមានលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ដូចខាងក្រោម :

១ - អ្នកសុំដីសម្បទានសង្គមកិច្ចសម្រាប់សង់លំនៅឋាន គឺជាមេគ្រួសារដែលគ្មានដីសម្រាប់សង់លំនៅឋាន និងគ្មានលទ្ធភាពរកដីដោយខ្លួនឯង ។

២ - អ្នកសុំដីសម្បទានសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ គឺជាគ្រួសារដែលគ្មានដីសម្រាប់ធ្វើកសិកម្ម ជាលក្ខណៈគ្រួសារឬមានដីដែរតែមានទំហំតូចជាងការកំណត់ទំហំដីសម្បទានសង្គមកិច្ច និងគ្មានលទ្ធភាពរក ដីដោយខ្លួនឯងហើយគ្មានមុខរបរក្រៅពីធ្វើកសិកម្ម ។

៣ - អ្នកសុំដីសម្បទានសង្គមកិច្ចដែលមានទ្រព្យសម្បត្តិផ្សេងៗ ជាមធ្យោបាយសម្រាប់រកប្រាក់ចំណូល ។ អ្នកសុំដីសម្បទានសង្គមកិច្ច ដូចមានចែងនៅក្នុងចំណុច ១ ចំណុច ២ និងចំណុច ៣ នៃប្រការ ៣ គឺ ជាអ្នកដែលមានប្រាក់ចំណូលប្រចាំថ្ងៃគិតជាមធ្យមក្នុងសមាជិកគ្រួសារម្នាក់ៗស្ថិតក្នុងស្ថានភាពក្រីក្រត្រូវបានត្រួតពិនិត្យផ្ទាល់ និងវាយតម្លៃពីអាជ្ញាធរ ភូមិ ឃុំ សង្កាត់ ដោយមានការចូលរួមពីសហគមន៍ចំពោះបណ្តាប្រភេទមុខរបរដែលមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ។

**ប្រការ៤ :** បណ្តាប្រភេទមុខរបរមានដូចខាងក្រោម :

| ល.រ | បរិយាយ មុខរបរ | ចំណូលប្រចាំថ្ងៃ គិតជាមធ្យម (គិតជារៀល) | ចំនួនថ្ងៃប្រកបរបរ ក្នុង ១ ខែ ( គិតជាថ្ងៃ ) | ចំនួនថ្ងៃ x ប្រាក់ ចំណូលប្រចាំថ្ងៃ | សរុបប្រាក់ ចំណូលតាម មុខរបរ ១ ខែ |
|---|---|---|---|---|---|
| ១ | រត់ម៉ូតូឌុប | | | | |
| ២ | បររទេះសេះ | | | | |
| ៣ | កម្មករសំណង់ | | | | |
| ៤ | កម្មករចំការកៅស៊ូ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥ | ស៊ីឈ្នួលធ្វើស្រែចំការ | | | | |
| ៦ | ប្រមូលអនុផលព្រៃឈើដើម្បីចិញ្ចឹមគ្រួសារ | | | | |
| ៧ | នេសាទជាលក្ខណៈគ្រួសារ | | | | |
| ៨ | ចាំចំការឱ្យគេ | | | | |
| ៩ | កាត់សក់ | | | | |
| ១០ | ប៉ះកង់-ម៉ូតូ | | | | |
| ១១ | មុខរបរផ្សេងទៀតដែលមានប្រភេទប្រហាក់ប្រហែលនឹងមុខរបរទាំង ១០ ខាងលើ | | | | |

**ប្រការ៥ :** លក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ ២ ប្រការ ៣ និងប្រការ ៤ ខាងលើ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំកសាងនូវបញ្ជីឈ្មោះគ្រួសារ ដែលបានដាក់ពាក្យសុំដីសម្បទានសង្គមកិច្ច និងសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យនូវបញ្ជីឈ្មោះ ដោយត្រូវកាត់ចេញនូវឈ្មោះគ្រួសារ ដែលបានទទួលដីសម្បទានសង្គមកិច្ចរួចហើយ ព្រមទាំងធ្វើបច្ចុប្បន្នភាពនូវស្ថានភាពខាងហិរញ្ញវត្ថុ នៃឈ្មោះគ្រួសារ ដែលមានក្នុងបញ្ជីឈ្មោះគ្រួសារ សុំដីសម្បទានសង្គមកិច្ចកន្លងមកដើម្បីឱ្យស្របទៅតាមលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ ។

**ប្រការ៦ :** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង និង ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវចូលរួមសហការជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ ខេត្ត-ក្រុង និងក្រុមការងារថ្នាក់ ស្រុក ខណ្ឌ ក្នុងការពិនិត្យលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច ដោយផ្អែក តាមសំណើរបស់អាជ្ញាធរភូមិ ឃុំ សង្កាត់ ។

រៀងរាល់ឆមាស និងបំណាច់ឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវចូលរួមសហការជាមួយអាជ្ញាធរភូមិ ឃុំ សង្កាត់ ក្នុងការរៀបចំបញ្ជីអ្នកសុំដីសម្បទានសង្គមកិច្ច ។

**ប្រការ៧ :** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម និងប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង និង ផ្នែកពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អ៊ិត សំហេង**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីគ្រប់ខេត្ត ក្រុង
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ